00505966

C20/9/15

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៣៣)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជី:**
សរ ចំន្ទារ៉ាត
Entela JOSIFI

**កាលបរិច្ឆេទ:** ៣០ ខែមេសា ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2010
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ (កោសល្យ)**

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀងធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 04 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY
យ៉េត ចរិយា
William SMITH
សេង ប៊ុនឃាង
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**
អៀង ធីរិទ្ធ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៣)

លេខ/No: C20/9/15

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

គីម ម៉េងឃី
ម៉ុច សុវណ្ណារី
នី ចាន់ឌី
ឡោ ជុនធី
គង់ ពិសី
ហុង គីមសួន
ស៊ិន សុវន
ជេត វណ្ណលី
ពេជ អង្គ
គង់ ហេង
សំ សុខគង់

Martine JACQUIN
Philippe CANONNE
Fabienne TRUSSES-NAPROUS
Elizabeth-Joelle RABESANDRATANA
Annie DELAHAIE
Silke STUDZINSKY
Mahdev MOHAN
NGUYEN Lyma
Marie GUIRAUD
Patrick BAUDOIN
Olivier BAHOUGNE
Julien RIVET
Pascal AUBOIN
Françoise GAUTRY
Isabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN

**សហមេធាវីការពារក្ដី**

**ជនត្រូវចោទ**

ផាត់ ពៅស៊ាង
Diana ELLIS

E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៣)

លេខ/No: C20/9/15

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់ [សហចៅក្រមស៊ើបអង្កេត] អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលោកស្រី អៀង ធីរិទ្ធ ដែលបានដាក់ជូនដោយសហមេធាវីការពារក្តីជនត្រូវចោទ អៀង ធីរិទ្ធ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨ (“បណ្តឹងឧទ្ធរណ៍”)[១]។

## I. **សាវតានីតិវិធី**

២. អង្គបុរេជំនុំជម្រះយោងទៅលើ បញ្ជាក់ឡើងវិញ និងអនុម័តរបាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង[២] ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០ ដែលបង្កើតបានជាផ្នែកនៃសាលដីកានេះ។

៣. នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចរបស់ខ្លួនអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន (“ដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួន”) ដោយបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្នលើ អៀង ធីរិទ្ធ ដែលត្រូវបានឃុំខ្លួន ចាប់តាំងពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧[៣]។

៤. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហមេធាវីការពារក្តីជនត្រូវចោទ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ហើយនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨ ពួកគាត់បានដាក់បណ្តឹងឧទ្ធរណ៍ ដែលបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨។

៥. នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះ (“ចម្លើយតបរបស់សហព្រះរាជអាជ្ញា”)[៤]។

---

[១] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨ C20/9/1 (“បណ្តឹងឧទ្ធរណ៍”)។

[២] របាយការណ៍នៃការត្រួតពិនិត្យសំណុំរឿង ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០ C20/9/6។

[៣] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ C20/8 (“ដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួន”)។

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចពន្យារថិរវេលាបន្ថែមនៃការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នរបស់ ក.ស.ច.ស ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ C20/9/2 (“ចម្លើយតបរបស់សហព្រះរាជអាជ្ញា”)។

៦. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់ចម្លើយតបឡើយ។

៧. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ប្រធានអង្គបុរេជំនុំជម្រះបានចេញដីកាសម្រេចកំណត់កាលបរិច្ឆេទសវនាការសាធារណៈទៅលើបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០[៥]។ មុនពេលសវនាការ អង្គបុរេជំនុំជម្រះត្រូវបានអនុញ្ញាតឱ្យពិនិត្យសំណុំរឿង ដែលបានធ្វើបច្ចុប្បន្នភាពរួច។

៨. នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានបើកសវនាការមួយ ដែលនៅពេលនោះជនត្រូវចោទត្រូវបានតំណាងដោយសហមេធាវីជាតិម្នាក់ និងមេធាវីអន្តរជាតិម្នាក់ មកពីក្រុមមេធាវីការពារក្តីរបស់លោកស្រី។ សវនាការនេះ ត្រូវបានធ្វើឡើងជា សាធារណៈ។

## II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៩. ដីកាសម្រេចលើការបន្តដីការឃុំខ្លួន ត្រូវបានចេញនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយ ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃដដែលនោះដែរ។ សហមេធាវីការពារក្តីជនត្រូវចោទ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩។ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូននៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ដូច្នេះគឺស្ថិតនៅក្នុងរយៈពេលដែលមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

## III. ច្បាប់ជាធរមាន

១០. ដោយយោងលើវិធាន៦៣ នៃវិធានផ្ទៃក្នុង ។

## IV. លក្ខណៈនៃបណ្តឹងឧទ្ធរណ៍

១១. នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលដីកាសម្រេចលើការបន្តដីការឃុំខ្លួន និងដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៦]។ ពួកគាត់បានអះអាងថា លក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងវិធាន ៦៣ នៃវិធានផ្ទៃក្នុងត្រូវបានសហចៅក្រមស៊ើបអង្កេតយកមកសម្រេចពុំបានត្រឹមត្រូវ ហើយទោះក្នុងកាលៈទេសៈណាក៏ដោយ

[៥] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ C20/9/3។

[៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨ និង ៣៩។

លក្ខខណ្ឌតម្រូវទាំងអស់នោះ លែងត្រូវបានបំពេញទៀតហើយ។ ពួកគាត់បានអះអាងថា "ភស្តុតាងដោះបន្ទុកដែលមានបូករួមជាមួយនឹងអង្គហេតុដែលថា ជនជាប់ចោទត្រូវបានតុលាការឃុំខ្លួនអស់រយៈពេលចំនួនជាងពីរឆ្នាំ និងអង្គហេតុដែលថា ការបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹងរូបគាត់នឹងខិតជិតមកដល់ក្នុងពេលឆាប់ៗនេះ បានធ្វើឱ្យការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទជាទង្វើមិនត្រឹមត្រូវ និងគ្មានយុត្តិកម្ម"[៧]។

១២. ក្នុងចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធបណ្ដឹងឧទ្ធរណ៍នេះ ដោយសម្អាងហេតុផលថា : ១) ដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបានផ្ដល់មូលហេតុយ៉ាងគ្រប់គ្រាន់ និងពេញលេញ ២) រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន គឺមានភាពសមស្រប និងគ្មានកង្វះកិច្ចខិតខំប្រឹងប្រែងពីសហចៅក្រមស៊ើបអង្កេតក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីនោះទេ ៣) ការលើកឡើងដែលថា សហចៅក្រមស៊ើបអង្កេតមិនមានភាពអនាគតិនោះ គឺមិនមានសុពលភាពទេ ៤) ដើមបណ្ដឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញអំពីកាលៈទេសៈប្រែប្រួលសត្យានុម័តនានា និង ៥) លក្ខខណ្ឌនានាសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ននាពេលបច្ចុប្បន្ននេះ នៅតែត្រូវបានបំពេញ[៨]។

១៣. ដោយពិចារណាលើការសម្រេចរបស់ខ្លួន ទាក់ទិនទៅនឹងបញ្ហានៃការឃុំខ្លួន[៩] និងសេចក្ដីសន្និដ្ឋាននានារបស់ភាគី ដូចដែលបានគូសបញ្ជាក់នៅក្នុងរបាយការណ៍ស្ដីពីការត្រួតពិនិត្យសំណុំរឿង អង្គបុរេជំនុំជម្រះនឹងពិនិត្យឡើងវិញ នូវដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួន ដោយធ្វើការពិនិត្យទៅលើ :

---

[៧] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៧។

[៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២ អនុកថាខណ្ឌ a-e។

[៩] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ C9/4/7។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ C20/5/18។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩, C22/5/38 និង សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំដោះលែង និង បន្តថិរវេលានៃដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ C26/5/26។

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

ក. មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)

ខ. មូលហេតុដែលការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ (វិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង)

គ. កិច្ចខិតខំប្រឹងប្រែងដ៏ត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេតក្នុងការដឹកនាំកិច្ចស៊ើបសួរ

ឃ. សំណើសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

## V. សេចក្ដីពិចារណា

**ក. មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)**

១៤. នៅក្នុងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា នៅក្នុងដីកាសម្រេចរបស់ពួកគាត់ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨[១០] ពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ និងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០០៩[១១] គេបានរកឃើញថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា អៀង ធីរិទ្ធ អាចបានប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានចោទប្រកាន់[១២]។

១៥. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ទៀតថា :

[១០] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ C20/4។

[១១] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ C20/5/17។

[១២] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ១១ ដល់១៣។

"ចាប់តាំងពី [សវនាការលើបណ្តឹងឧទ្ធរណ៍ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩] សហចៅក្រមស៊ើបអង្កេតបានបន្តអង្កេតលើការចោទប្រកាន់ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដាក់ភស្តុតាងទៅក្នុងសំណុំរឿង។ ចម្លើយសាក្សីថ្មីៗចំនួនម្តងមួយ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងដែលជួយបញ្ជាក់ថា តើជនត្រូវចោទបានដើរតួនាទីជាប់ពាក់ព័ន្ធយ៉ាងណានឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់"[១៣]។

១៦. នៅក្នុងកថាខណ្ឌដដែលនោះដែរ សហចៅក្រមស៊ើបអង្កេតបានបន្តបញ្ជាក់អំពីភស្តុតាងដែលពួកគាត់ពិចារណាថាមានលក្ខណៈដាក់បន្ទុក។ ពួកគាត់បញ្ជាក់ថា ភស្តុតាងខ្លះអាចមានលក្ខណៈដោះបន្ទុក ប៉ុន្តែពួកគាត់យល់ឃើញថា ភស្តុតាងនេះគឺមិនមានលក្ខណៈគ្រប់គ្រាន់ ក្នុងការច្រានចោលសម្មតិកម្មដែលថា ជនត្រូវចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានចោទប្រកាន់ឡើយ[១៤]។

១៧. សហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានថា :

"បន្ទាប់ពីបានពិនិត្យឡើងវិញលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង នៅត្រឹមដំណាក់កាលនៃកិច្ចស៊ើបសួរនេះ មានការលេចឡើងនូវអង្គហេតុ និងព័ត៌មានបន្ថែមនានា ដែលអាចឲ្យអ្នកសង្កេតការណ៍អព្យាក្រឹត្យជឿបានថា នៅក្នុងមុខងារ និងតួនាទីមួយ ឬច្រើនរបស់គាត់ មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា អៀង ធីរិទ្ធ បានរៀបចំផែនការ ញុះញង់ បញ្ជា មិនបានព្យាយាមទប់ស្កាត់ ឬបានជួយ និងជំរុញឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ដូចមានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដូច្នេះលក្ខខណ្ឌដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង នៅតែត្រូវបានបំពេញ ទោះបីជាមានការកន្លង ផុតទៅនៃពេលវេលាក្តី"[១៥]។

១៨. ដោយបានរកឃើញថា ភស្តុតាងខ្លះ "គឺ" មានលក្ខណៈដាក់បន្ទុក ហើយភស្តុតាងខ្លះទៀត "អាចហាក់ដូចជាមាន"លក្ខណៈដោះបន្ទុក សហមេធាវីការពារក្តីបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគាត់ថា សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់បទដ្ឋានមួយផ្សេងនៅក្នុងករណីទាំងពីរនេះ ហើយដូច្នេះ បានខកខានពុំបានអនុវត្តតួនាទីដោយមិនលម្អៀង និងពុំបានវាយតម្លៃភស្តុតាងឲ្យ

[១៣] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ១៤។

[១៤] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ១៥ ដល់១៦។

[១៥] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ១៧។

បានត្រឹមត្រូវ និងប្រកបដោយយុត្តិធម៌តាមលក្ខខណ្ឌតម្រូវអនុលោមតាមវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង។ ដោយដកស្រង់នូវសម្រង់ចេញពីការស្តាប់ចម្លើយ ដែលបានធ្វើឡើងជាមួយ [redacted] នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ដែលមិនបានបញ្ជាក់នៅក្នុងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួន សហមេធាវីការពារក្តីបានបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេត "ខកខានពុំបានពិចារណារាល់ភស្តុតាងពាក់ព័ន្ធទាំងអស់ នៅមុនពេលពួកគេធ្វើសេចក្តីសម្រេច ទាក់ទិននឹងអត្ថិភាពនៃមូលហេតុ ដែលត្រូវបានរកឃើញយ៉ាងច្បាស់"។ សហមេធាវីការពារក្តីសន្និដ្ឋានថា ស្ថិតក្រោមកាលៈទេសៈខាងលើនេះ មិនអាចមានការសន្និដ្ឋានថា មានអង្គហេតុ ឬព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើឱ្យអ្នកសង្កេតការណ៍អព្យាក្រឹត្យជឿជាក់បានឡើយថា ជនត្រូវចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានចោទប្រកាន់នោះ[១៦]។ នៅក្នុងសវនាការ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្តីបានបន្ថែមថា របាយការណ៍បញ្ចប់នៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសថ្មីៗនេះ D231 ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ផ្តល់នូវចំនួនគ្រប់គ្រាន់នៃភស្តុតាងដោះបន្ទុក និងពន្យល់អំពីរយៈពេលដ៏យូរដែលសហចៅក្រមស៊ើបអង្កេតបានប្រើ ដើម្បីដាក់ភស្តុតាងទាំងនោះទៅក្នុងសំណុំរឿង[១៧]។

១៩. នៅក្នុងចម្លើយតបរបស់ពួកគាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គបុរេជំនុំជម្រះ គួរតែពិចារណាមិនត្រឹមតែទៅលើភស្តុតាងថ្មីដែលត្រូវបានដាក់ ចាប់តាំងពីមានដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនប៉ុណ្ណោះទេ ប៉ុន្តែគួរពិចារណាផងដែរនូវអង្គហេតុ ដែលជនត្រូវចោទត្រូវបានជូនដំណឹងអំពីបទចោទបន្ថែម នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩[១៨]។ សហព្រះរាជអាជ្ញាក៏បានបញ្ជាក់ផងដែរ ក្នុងអំឡុងសវនាការថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ថា នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេច អំពីការអនុវត្តទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម[១៩]។ សហព្រះរាជអាជ្ញាអះអាងថា ភស្តុតាងសរុបទាំងអស់ដែលប្រមូលបាន រហូតមកដល់បច្ចុប្បន្ននេះបង្ហាញថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋ ដូចដែលបានចោទ

---

[១៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៤ ដល់២១។

[១៧] ប្រតិចារឹកអំពីសវនាការថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីបណ្តឹងឧទ្ធរណ៍ ឯកសារ C20/9 កថាខណ្ឌ១៨ ដល់១៩។

[១៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៨។

[១៩] ប្រតិចារឹកអំពីសវនាការថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីបណ្តឹងឧទ្ធរណ៍ ឯកសារ C20/9 កថាខណ្ឌ៤៩ ដល់៥០។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ប្រកាន់។ ទាក់ទិនទៅនឹងចម្លើយរបស់ [redacted] ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានលើកឡើងថា គេគួរពិចារណារួមគ្នាជាមួយភស្តុតាងដែលនៅសេសសល់ដទៃទៀត ក្នុងបរិបទទូលាយជាងនេះ ដោយបន្ថែមថា មានភស្តុតាងដាក់បន្ទុក ពាក់ព័ន្ធដោយផ្ទាល់ជាច្រើននៅក្នុងសំណុំរឿង[២០]។

២០. ទាក់ទិនទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីបទចោទបន្ថែម អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានចេញនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបំភ្លឺអំពីបទចោទប្រឆាំងនឹងជនត្រូវចោទនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ជាភាសាអង់គ្លេស ដែលដីកាសម្រេចនេះត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨[២១]។

២១. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៨ ក្នុងអំឡុងការស្តាប់ចម្លើយជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងសហមេធាវីរបស់គាត់អំពីបទចោទ ដែលជនត្រូវចោទអាចត្រូវបានចោទប្រកាន់ ដោយបានចង្អុលបង្ហាញថា "មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា អំពើដែលបានប្រព្រឹត្តត្រូវចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មក្នុងបទល្មើសជាតិ"[២២]។ សហចៅក្រមស៊ើបអង្កេតមានប្រសាសន៍ថា ពួកគាត់ "បានជូនដំណឹងរួចហើយដល់ [ជនត្រូវចោទ] អំពីបទចោទប្រកាន់ នាពេលបង្ហាញមុខជាលើកដំបូង ហើយបន្ទាប់ពីពិនិត្យមើលភស្តុតាងរួចមក ឥឡូវនេះ [ពួកគាត់] ពិចារណាថា បទចោទប្រកាន់បន្ថែមគឺជាលក្ខណៈមួយត្រឹមត្រូវ"[២៣]។ ដោយឡែកនៅពេលបង្ហាញមុខជាលើកដំបូង ជនជាប់ចោទ "ត្រូវប្រាប់ឱ្យដឹងថា លោកស្រី [...] ស្ថិតនៅក្រោមការស៊ើបអង្កេតចំពោះអំពើសកម្ម ឬអកម្ម ដែលលោកស្រីត្រូវបានជូនដំណឹងឱ្យដឹង និងបានបញ្ជាក់អំពីបទល្មើសនានា ដែលលោកស្រីត្រូវបានចោទប្រកាន់ ទាក់ទិនទៅនឹងបទល្មើស : ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [...] បទល្មើសដែលមាន

---

[២០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៩ ដល់២៣។

[២១] ដីកាពាក់ព័ន្ធនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំបំភ្លឺអំពីការចោទប្រកាន់នានា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D198/1 ("ដីកាស្តីពីការបំភ្លឺអំពីការចោទប្រកាន់")។

[២២] កំណត់ហេតុនៃការសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D286 កថាខណ្ឌ៥។

[២៣] កំណត់ហេតុនៃការសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D286 កថាខណ្ឌ១០។

ចែង និងផ្តន្ទាទោសក្រោមមាត្រា ៥ មាត្រា៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥"[២៤]។

២២. ដើម្បីផលប្រយោជន៍យុត្តិធម៌ អង្គបុរេជំនុំជម្រះបញ្ជាក់អំពីសាលដីកាលើកមុនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[២៥]។ អង្គបុរេជំនុំជម្រះរកឃើញថា នៅពេលដែលធាតុផ្សំនៃអង្គហេតុពិតជាដូចគ្នា នោះទើបគេអាចអះអាងថា បទឧក្រិដ្ឋផ្សេងៗទៀត ត្រូវបានដាក់បញ្ចូលនៅក្នុងបទចោទ ហើយនៅពេលដែលធាតុផ្សំមានលក្ខណៈខុសគ្នា បទឧក្រិដ្ឋផ្សេងៗទៀតមិនត្រូវបានដាក់បញ្ចូលឡើយ[២៦]។ នៅក្នុងសាលដីកាដដែលនេះដែរ អង្គបុរេជំនុំជម្រះយល់ឃើញថា បទល្មើសតាមច្បាប់ជាតិមានធាតុផ្សំ ខុសគ្នាពីបទល្មើសតាមច្បាប់អន្តរជាតិ[២៧]។ អង្គបុរេជំនុំជម្រះក៏បានរកឃើញផងដែរថា យោងតាមបទដ្ឋានអន្តរជាតិ ជនត្រូវចោទត្រូវតែមានសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទដាច់ដោយឡែកពីគ្នាទាំងអស់ ប្រឆាំងរូបគាត់ឱ្យបានឆាប់ នៅពេលដែលបទចោទទាំងនោះ ត្រូវបានបង្ហាញយុត្តិកម្ម "ត្រឹមកម្រិតមួយដែលអាចឱ្យគាត់អនុវត្តសិទ្ធិដែលផ្តល់ជូនគាត់ក្នុងអំឡុងពេលនៃការស៊ើបសួរ រួមទាំងសិទ្ធិស្នើសុំឱ្យបើកកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង"[២៨]។

២៣. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីជំទាស់ទៅនឹងអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចមានការទទួលខុសត្រូវ ចំពោះបទឧក្រិដ្ឋទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេត ដោយបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតខកខានពុំបានអនុវត្តតួនាទីដោយមិនលម្អៀង និងពុំបានវាយតម្លៃភស្តុតាងឱ្យបានត្រឹមត្រូវ និងប្រកបដោយយុត្តិធម៌ឡើយ ដោយឱ្យតម្លៃទៅលើភស្តុតាងដាក់បន្ទុកច្រើនជាង ហើយមិនបានពិចារណាទៅលើភស្តុតាងខ្លះដែលមានលក្ខណៈដោះបន្ទុក

---

[២៤] កំណត់ហេតុនៃការចូលខ្លួនដំបូង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ D39 កថាខណ្ឌ២ និង៣។

[២៥] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅ ជំនុំជម្រះ")។

[២៦] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៨៥ និង៨៨។

[២៧] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៦០ ដល់៨៨។

[២៨] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ១៣៨។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ឡើយ។ ក្នុងបញ្ហានេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេត: បានពិនិត្យឡើងវិញលើភស្តុតាង ដែលមាននៅក្នុងសំណុំរឿង រួមទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[២៩] បានពិចារណាលើសម្ភារៈពាក់ព័ន្ធដែលមាននៅក្នុងសំណុំរឿង និងបានធ្វើការសន្និដ្ឋានថា មូលហេតុដែលត្រូវបានរកឃើញនៅតែមាននៅឡើយ។ ពាក្យពេចន៍ដែលសហចៅក្រមស៊ើបអង្កេតបានប្រើ ដើម្បីពណ៌នាអំពី ភស្តុតាងដោះបន្ទុក ថា វា "ទំនងជាមានលក្ខណៈដោះបន្ទុកនោះ" កំពុងបង្ហាញនូវការយល់ដឹងអំពីការថ្លឹងថ្លែងដែលគួរត្រូវបានផ្តល់ទៅលើភស្តុតាងបែបនេះ នៅក្នុងគ្រប់ភស្តុតាង សរុបទាំងអស់ ដែលត្រូវបានពិនិត្យ។

២៤. ដូចដែលបានចង្អុលបង្ហាញដោយសហមេធាវីការពារក្តីដូច្នោះដែរ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ភស្តុតាងដែលអាចជាភស្តុតាងដោះបន្ទុកផ្សេងទៀត ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង នៅមុនពេលដែលដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនបានដាក់ចេញ[៣០]។ បន្ទាប់ពីបានពិចារណាទៅលើចំនួនសរុបនៃភស្តុតាងដែលមាននៅក្នុងសំណុំរឿង រហូតដល់ពេលដែលដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនបានដាក់ចេញ អង្គបុរេជំនុំជម្រះយល់ឃើញថា ចំណែកនៃភស្តុតាងនេះ មិនប៉ះពាល់ដល់ការសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមានភាពត្រឹមត្រូវក្នុងការយល់ឃើញថា មានហេតុផលសមស្របដែលនាំឲ្យជឿបានថា ជនត្រូវចោទត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនានា ដែលរូបគាត់កំពុងស្ថិតនៅក្រោមការស៊ើបអង្កេតនោះ។ អង្គហេតុដែលថា ការសួរយកចម្លើយជនត្រូវចោទ [redacted] កាលពីថ្ងៃ ទី២០ ខែតុលា ឆ្នាំ២០០៩ មិនត្រូវបានលើកឡើង នៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួននោះ មិនមានន័យសំខាន់ថា សហចៅក្រមស៊ើបអង្កេតមិនបានពិនិត្យមើលការសួរយកចម្លើយនោះទេ។ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាទៅលើការសួរយកចម្លើយនេះ ដោយពិនិត្យមើលភស្តុតាង *ជាថ្មី*។

២៥. ពាក់ព័ន្ធទៅនឹងសហមេធាវីដែលបានតវ៉ាអំពីរយៈពេលយូរ ដែលសហចៅក្រមស៊ើបអង្កេតដាក់របាយការណ៍បញ្ចប់ការអនុវត្តតាមដីកាចាត់ឲ្យស៊ើបសួរជំនួស D231 ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ

[២៩] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ១៤ ដល់១៧។

[៣០] កំណត់ហេតុសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ឯកសារ D225។

២០០៩ នៅក្នុងសំណុំរឿងនោះ[៣១] អង្គបុរេជំនុំជម្រះសង្កេតឃើញទីមួយថា សហមេធាវីការពារក្តីមិនបានយោងលើភស្តុតាងជាក់លាក់នៅក្នុងសំណុំរឿងនោះទេ និងទីពីរ យល់ឃើញថា ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍នេះ បញ្ហានេះគ្មានផលវិបាកអ្វីឡើយនៅពេលដែលអង្គបុរេជំនុំជម្រះបានពិនិត្យមើលនោះ ភស្តុតាង*ជាថ្មី* និងពិនិត្យលើរបាយការណ៍បញ្ចប់ការអនុវត្តតាមដីកាចាត់ឱ្យស៊ើបសួរជំនួសនៅពេលពិចារណាថាតើមានហេតុផលសមស្របដែលនាំឱ្យជឿបានថា ជនត្រូវចោទបានប្រព្រឹត្តបទឧក្រិដ្ឋនានាដែលគាត់ត្រូវបានចោទប្រកាន់ដែរឬទេនោះ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីជនត្រូវចោទអាចផ្តល់មតិយោបល់ទៅលើខ្លឹមសារនៃដីកាចាត់ឱ្យស៊ើបសួរជំនួសនេះបាន ទោះបីជាសហមេធាវីការពារក្តីជ្រើសរើសមិនធ្វើក៏ដោយ។

២៦. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន បានត្រឹមត្រូវក្នុងការសន្និដ្ឋានថា "មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់" នៅតែមាន។

២៧. បន្ទាប់ពីបានមើលសំណុំរឿង*ជាថ្មី* អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនយល់ឃើញថា មានចម្លើយ និងឯកសារថ្មីៗដែលបានដាក់នៅក្នុងសំណុំរឿងដែលមានភស្តុតាងដែលមានលក្ខណៈដោះបន្ទុក[៣២] និងមានលក្ខណៈដាក់បន្ទុក[៣៣]។ បន្ទាប់ពីបានពិនិត្យចំនួនសរុបនៃភស្តុតាងរួចមក អង្គ

---

[៣១] អង្គបុរេជំនុំជម្រះសង្កេតឃើញថា របាយការណ៍បញ្ចប់ការអនុវត្តតាមដីកាចាត់ឱ្យស៊ើបសួរជំនួស D231 ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០០៩ ត្រូវបានដាក់ជាភាសាដើម ភាសាខ្មែរ និងបានបកប្រែជាភាសាបារាំង និងភាសាអង់គ្លេស កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។

[៣២] [redacted]

[៣៣] [redacted]

បុរេជំនុំជម្រះយល់ឃើញថា ភស្តុតាងដោះបន្ទុកថ្មីនឹងមិនប៉ះពាល់ដល់ការសន្និដ្ឋាន ដែលមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់នោះទេ នាពេលនេះ។

២៨. អង្គបុរេជំនុំជម្រះយល់ឃើញថា មិនគ្រាន់តែមាន "មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់" ដែលនឹងធ្វើឱ្យអ្នកសង្កេតការសត្យានុម័តជឿជាក់ថា ជនត្រូវចោទអាចមានការទទួលខុសត្រូវចំពោះ ឬបានប្រព្រឹត្តបទឧក្រិដ្ឋនានា ដែលបានគូសបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដូចដែលបានបញ្ជាក់ការពិតដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនប៉ុណ្ណោះទេ មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់នេះ ថែមទាំងត្រូវបានគាំទ្រដោយភស្តុតាងបន្ថែមទៀតផង នាពេលនេះ។

២៩. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌទីមួយសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង នៅតែត្រូវបានបំពេញ។

**ខ. ការពិចារណាលើមូលដ្ឋានដែលធ្វើឱ្យការឃុំខ្លួនបណ្តោះអាសន្នក្លាយជាវិធានការចាំបាច់ (វិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង)**

៣០. នៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន សហចៅក្រមស៊ើបអង្កេតបានយោងលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ

[redacted]

ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០០៩[៣៤] និងបានពិចារណាថាតើលក្ខខណ្ឌនានាស្របតាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង នៅតែត្រូវបានគេជឿជាក់ដែរឬទេ។ សហចៅក្រមស៊ើបអង្កេតយល់ឃើញ នៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនថា ដោយសារតែគ្មានអ្វីប្រែប្រួលនៅក្នុងកាលៈទេសៈនានា និងដោយសារតែក្រុមមេធាវីការពារក្តីមិនបានរៀបចំអ្វីដែលបង្ហាញពីការជំទាស់ទេនោះ ការឃុំខ្លួននៅតែជាវិធានការចាំបាច់ ដើម្បីរាំងជនត្រូវចោទមិនឱ្យដាក់ការគាបសង្កត់លើសាក្សី ឬជនរងគ្រោះនានា ដើម្បីរក្សាភស្តុតាង ដើម្បីធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងកិច្ចដំណើរការនីតិវិធី និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ[៣៥]។

៣១. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងការអនុវត្តបទដ្ឋាននេះ សហចៅក្រមស៊ើបអង្កេតបានដើរតួនាទីបានត្រឹមត្រូវ។

<u>ហានិភ័យនៃការដាក់ការគាបសង្កត់លើសាក្សីនានា និងបំផ្លាញភស្តុតាង ប្រសិនបើត្រូវបានដោះលែង (វិធាន ៦៣(៣)(ខ)(i) និង (ii) នៃវិធានផ្ទៃក្នុង):</u>

៣២. នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតគួរតែធ្វើការពិចារណាអំពីអង្គហេតុដែលថាជនត្រូវចោទមិនបានផ្តល់នូវការបង្ហាញថា ខ្លួនខិតខំជ្រៀតជ្រែក ឬរាំងស្ទះកិច្ចការរដ្ឋបាលដោយផ្ទាល់ ឬដោយប្រយោល ទោះបីជាខ្លួនបានស្គាល់ឈ្មោះរបស់សាក្សីសំខាន់ៗជាច្រើននាក់តាមរយៈការស៊ើបអង្កេតក៏ដោយ។ សហមេធាវីការពារក្តីបានបន្ថែមថា អង្គហេតុដែលថា ការបិទកិច្ចស៊ើបសួរខិតជិតមកដល់ហើយ មានន័យថា វាមិនចាំបាច់រក្សាការឃុំខ្លួនជនត្រូវចោទ ដើម្បីធានានូវសុចរិតភាពនៃកិច្ចស៊ើបសួរតទៅទៀតឡើយ។

៣៣. សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា អាកប្បកិរិយាប្រមាថមើលងាយរបស់ជនត្រូវចោទដែលពោរពេញដោយការគំរាមកំហែង និងប៉ុនប៉ងបំភ័យភាគីនានានៅពេលសវនាការ ឬនៅក្នុងមន្ទីរឃុំឃាំងនោះ បង្ហាញឱ្យឃើញថា ជនត្រូវចោទបានបង្ហាញយ៉ាងច្បាស់លាស់អំពីសក្តានុពលរបស់គាត់ ក្នុងការដាក់ការគាបសង្កត់ប្រឆាំងទៅនឹងសាក្សីព្រមទាំងជនរងគ្រោះទាំងឡាយ ប្រសិនបើ

---

[៣៤] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០០៩ ឯកសារលេខ C20/5/18។

[៣៥] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ១៨ ដល់ ២៦។

PRE-TRIAL CHAMBER · E.C.C.C · C.E.T.C · CHAMBRE PRÉLIMINAIRE

គាត់ត្រូវបានដោះលែង[៣៦]។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា សុចរិតភាពនៃកិច្ចស៊ើបសួរនៅតែអាចមានផលអាក្រក់ ទោះបីជាក្រោយពេលបិទកិច្ចស៊ើបសួរទាំងឡាយហើយក៏ដោយ ពីព្រោះអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង សាក្សីនានានៅតែអាចត្រូវបានស្តាប់យកចម្លើយនៅចន្លោះពេលបិទកិច្ចស៊ើបសួរ និងពេលចេញដីកាដំណោះស្រាយ ហើយសហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថែមទៀតថា សាក្សីនានានឹងត្រូវបានស្តាប់យកចម្លើយ នៅក្នុងពេលសវនាការ[៣៧]។

៣៤. ដូចដែលបានសង្កេតឃើញដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនដែរ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ជនត្រូវចោទបានទទួលនូវភស្តុតាងដែលមានសេចក្តីពិស្តារស្តីពីឈ្មោះរបស់សាក្សីនានា តាមរយៈមេធាវីរបស់គាត់។ ទោះបីជា សហចៅក្រមស៊ើបអង្កេតរកឃើញថា គ្មានអ្វីប្រែប្រួលនៅក្នុងកាលៈទេសៈនានាក៏ដោយ នៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន សហចៅក្រមស៊ើបអង្កេតមិនបានពន្យល់ច្បាស់លាស់អំពីថា តើការដឹងអំពីសេចក្តីពិស្តារស្តីពីឈ្មោះរបស់សាក្សីនានារបស់ជនត្រូវចោទនៅតែមានហានិភ័យប៉ុណ្ណា ចំពោះសុចរិតភាពនៃកិច្ចស៊ើបសួរនៅដំណាក់កាលនេះឡើយ។

៣៥. ដូចដែលបានចង្អុលបង្ហាញដោយសហព្រះរាជអាជ្ញាផងដែរ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ប្រវត្តិនៃអាកប្បកិរិយាប្រមាថមើលងាយរបស់ជនត្រូវចោទរួមជាមួយនឹងអង្គហេតុដែលថា សាក្សីនៅតែអាចត្រូវបានស្តាប់យកចម្លើយនៅចន្លោះពេលបិទកិច្ចស៊ើបសួរ និងពេលចេញដីកាដំណោះស្រាយ និងនៅក្នុងពេលសវនាការនោះ ផ្តល់យុត្តិកម្មដល់ការសន្និដ្ឋានថា នៅតែមានសេចក្តីត្រូវការធ្វើការរារាំងការគាបសង្កត់ដែលអាចមាន ដែលអាចធ្វើឡើងដោយជនត្រូវចោទទៅលើសាក្សីព្រមទាំងជនរងគ្រោះនានា ប្រសិនបើគាត់ត្រូវបានដោះលែងនោះ។ មូលហេតុទាំងអស់នេះ ត្រូវដាក់បញ្ចូលទៅក្នុងកថាខណ្ឌ ដែលពាក់ព័ន្ធនៅក្នុងការបញ្ជាក់ហេតុផលនៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន[៣៨]។

[៣៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៧ ដល់២៩។

[៣៧] ប្រតិចារឹកអំពីសវនាការថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីបណ្តឹងឧទ្ធរណ៍ ឯកសារ C20/9 ទំព័រទី៥៥ ដល់៥៦។

[៣៨] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ២០ ដល់២២។

៣៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែមានភាពចាំបាច់ ដើម្បីរារាំងជនត្រូវចោទមិនឱ្យដាក់ការគាបសង្កត់លើសាក្សី ឬជនរងគ្រោះនានា និងមិនឱ្យបំផ្លាញភស្តុតាង។ ដូចនេះ មូលដ្ឋាននានាដែលបានលើកឡើងនៅក្នុងវិធាន ៦៣(៣)(ខ)(i) និង (ii) នៃវិធានផ្ទៃក្នុង នៅតែត្រូវបានបំពេញ។

<u>ភាពចាំបាច់ដើម្បីធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងកិច្ចដំណើរការនីតិវិធី</u>

<u>(វិធាន ៦៣(៣)(ខ)(iii) នៃវិធានផ្ទៃក្នុង):</u>

៣៧. សហមេធាវីបានលើកទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា លក្ខខណ្ឌសុខភាព និងសេចក្តីត្រូវការឱ្យមានការព្យាបាលជម្ងឺបន្តទៀតរបស់ជនត្រូវចោទ ធ្វើឱ្យការសន្និដ្ឋានដែលថា ប្រសិនបើជនត្រូវចោទត្រូវបានដោះលែង គាត់នឹងអាចគេចខ្លួននោះមានភាពមិនប្រាកដនិយមនោះទេ[៣៩]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍នេះគ្មានភាពគួរឱ្យជឿជាក់នោះទេ ពីព្រោះផ្អែកលើការទាក់ទង និងលទ្ធភាពដែលជនត្រូវចោទមាន គាត់អាចនឹងស្វែងរកការព្យាបាលជម្ងឺបានគ្រប់គ្រាន់នៅទីកន្លែងផ្សេង ប្រសិនបើគាត់ត្រូវបានដោះលែង។

៣៨. ដោយយល់ឃើញអំពីស្ថានទម្ងន់នៃបទចោទនានា អង្គបុរេជំនុំជម្រះសង្កេតឃើញថែមទៀតថា ជនត្រូវចោទអាចប្រឈមមុខនឹងការផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំឆ្នាំដល់មួយជីវិត ប្រសិនបើត្រូវបានរកឃើញថាមានពិរុទ្ធភាព។ រហូតមកទល់ពេលនេះ គ្មានអ្វីមួយត្រូវបានដាក់ចូលក្នុងសំណុំរឿងដែលនាំឱ្យមានការសន្និដ្ឋានថា មានកាលៈទេសៈប្រែប្រួលនោះឡើយ។ លើសពីនេះទៀត ភស្តុតាងថ្មីដែលបានដាក់ចូលក្នុងសំណុំរឿង បានបន្ថែមទឡ្ហីករណ៍ដែលគាំទ្រដល់ការទាក់ទងគ្នា រវាងអំពើនានាដែលត្រូវបានចោទប្រកាន់ជាមួយនឹងជនត្រូវចោទ ដូចនេះបានដាក់ស្ថានទម្ងន់ទៅលើជនត្រូវចោទកាន់តែខ្លាំងឡើង[៤០]។

៣៩. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតធ្វើត្រឹមត្រូវហើយក្នុងការសន្និដ្ឋានថា នៅតែមានសេចក្តីត្រូវការរក្សាការឃុំខ្លួនជនត្រូវចោទ ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធី។

---

[៣៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៦ ដល់២៩។

[៤០] សូមមើលកថាខណ្ឌទី២៧ និងជើងទំព័រទី៣៣ ខាងលើ។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ភាពចាំបាច់ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈ (វិធាន ៦៣(៣)(ខ)(v)) នៃវិធានផ្ទៃក្នុង:

៤០. ដោយយោងតាមសាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR) សហមេធាវីការពារក្តីបានលើកទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា ដើម្បីធ្វើឱ្យការឃុំខ្លួនមានយុត្តិកម្ម តម្រូវឱ្យមាន "អង្គហេតុនានាដែលត្រូវបង្ហាញថា ការដោះលែងជនត្រូវចោទពិតជានឹងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ" និងថា គ្មានអង្គហេតុទាំងនេះនៅក្នុងរឿងក្តីនេះទេ[៤១]។ បន្ទាប់ពីបានត្រិះរិះលើឯកសារយោងនានាដែលមាននៅក្នុងសំណុំរឿងរួចមក[៤២] នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងថា ពិតជាមានអង្គហេតុទាំងនេះ និងថា សហមេធាវីការពារក្តីមិនបានបង្ហាញនូវអ្វីដែលជាការជំទាស់ទាល់តែសោះ។ នៅក្នុងសារណាតប នៅក្នុងពេលសវនាការថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្តីបានលើកឡើងថា មានប្រជាជនកម្ពុជាតែ ៥% ប៉ុណ្ណោះដែលមានអាយុលើសពី ៥០ឆ្នាំ និងមានជម្ងឺបាក់ស្បាត (Post Traumatic Stress Disorder-PTSD) ដែលកើតមកពីរបបកម្ពុជាប្រជាធិបតេយ្យ និងថា ប្រជាជនភាគច្រើននឹងជាសះស្បើយពីជម្ងឺនេះក្នុងរយៈពេលបីខែក្រោយ[៤៣]។

៤១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហមេធាវីការពារក្តីមិនបានរៀបចំឯកសារគាំទ្រណាមួយសម្រាប់ទឡ្ហីករណ៍របស់ខ្លួនដែលបានលើកឡើងនៅក្នុងពេលសវនាការថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ២០១០ នោះឡើយ។ ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន និងឯកសារទាំងឡាយដែលបានយោងដោយសហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរបស់ខ្លួន[៤៤] គ្រប់គ្រាន់នឹងបង្ហាញថា ការដោះលែងជនត្រូវចោទ ពិតជានឹងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

[៤១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៣២ ដល់ទី៣៣។

[៤២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣០។

[៤៣] ប្រតិចារឹកអំពីសវនាការថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីបណ្តឹងឧទ្ធរណ៍ ឯកសារ C20/9 ទំព័រទី៦៦។

[៤៤] អង្គបុរេជំនុំជម្រះសង្កេតឃើញថា ខុសប្លែកពីរឿងក្តីនេះ នៅក្នុងរឿងក្តី Lettelier និង Tomasi នៅចំពោះមុខ ECHR ដែលជាករណីដែលសហមេធាវីការពារក្តីបានយោង មានតែទឡ្ហីករណ៍ដែលប្រើដោយរដ្ឋអាជ្ញាប៉ុណ្ណោះដែលគាំទ្រដល់ការបន្តការឃុំខ្លួនដែលជាវិធានការចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈនៅក្នុងរឿងក្តីទាំងពីរនោះ គឺ "ស្ថានទម្ងន់នៃបទល្មើស" ដែលនៅក្នុងរឿងក្តីនៅចំពោះមុខតុលាការនេះ ទឡ្ហីករណ៍ដែលបានរៀបចំដោយរដ្ឋអាជ្ញាគឺហួសពី "ស្ថានទម្ងន់នៃបទល្មើស" ទៅទៀត។

00505983



៤២. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតធ្វើត្រឹមត្រូវហើយក្នុងការសន្និដ្ឋានថា នៅតែមានសេចក្ដីត្រូវការរក្សាការឃុំខ្លួនជនត្រូវចោទ ដើម្បីចៀសវាងការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ។

<u>សន្និដ្ឋាន:</u>

៤៣. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ននៅតែជាវិធានការចាំបាច់ ដើម្បី (i) រារាំងជនត្រូវចោទមិនឲ្យដាក់ការគាបសង្កត់លើសាក្សី ឬជនរងគ្រោះនានា (ii) ថែរក្សាភស្ដុតាង (iii) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងកិច្ចដំណើរការនីតិវិធី និង (iv) រក្សាសណ្ដាប់ធ្នាប់សាធារណៈ។

**គ. ការយកចិត្តទុកដាក់ពីសំណាក់សហចៅក្រមស៊ើបអង្កេត**

៤៤. នៅក្នុងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា "ការកន្លងផុតទៅនៃពេលវេលាគឺជាកត្តាកំណត់អំពីការបន្តការឃុំខ្លួនជនត្រូវចោទ"[៤៥]។ សហចៅក្រមស៊ើបអង្កេតបានបង្ហាញថា វិសាលភាពនៃកិច្ចស៊ើបសួរដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ព្រមទាំងស្ថានទម្ងន់នៃបទឧក្រិដ្ឋនានា ដែលចោទប្រកាន់ចំពោះជនត្រូវចោទ គឺតម្រូវឲ្យមានការរៀបចំនូវកិច្ចស៊ើបសួរដែលមានទំហំធំ។ សហចៅក្រមស៊ើបអង្កេតក៏បានត្រិះរិះថែមទៀតលើកិច្ចស៊ើបសួរនៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន ដែលបានធ្វើឡើងកាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ដែល រួមបញ្ចូលនូវកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និងការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងឯកសារនានាដែលបានដាក់ចូលក្នុងសំណុំរឿងតាមរយៈសំណើសុំរបស់ភាគីនានា ឬតាមរយៈ*ការផ្ដួចផ្ដើមផ្ទាល់*[៤៦]។

៤៥. សហមេធាវីបានលើកទឡ្ហីករណ៍ថា ការពិចារណារបស់សហចៅក្រមស៊ើបអង្កេតដែលថា ដោយពិចារណាអំពីសម្ភារៈនានាដែលបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿង សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការកន្លងផុតទៅនៃពេលវេលាពុំចាំបាច់ទាមទារឲ្យមានការពន្យល់អំពីការចាំបាច់ក្នុងការបន្តថិរវេលានៃការឃុំខ្លួនជនជាប់ចោទនោះ មិនមានការពាក់ព័ន្ធឡើយ។ សហមេធាវី

---

[៤៥] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ២៧។

[៤៦] ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួន កថាខណ្ឌ២៨ ដល់៣០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. E.T.C.

ការពារក្តីបានអះអាងជាថ្មីអំពីភាពជឿជាក់របស់ខ្លួនលើ "លក្ខខណ្ឌតម្រូវឱ្យមានការយកចិត្តទុកដាក់ពិសេស"[៤៧]។

៤៦. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ក្រុមមេធាវីការពារក្តីមិនបានបង្ហាញថាតើរយៈពេលនៃការឃុំខ្លួននេះ បានប៉ះពាល់ដល់ករណីរបស់ភាគីដើមបណ្តឹងឧទ្ធរណ៍ដោយរបៀបណា ដែលធ្វើឱ្យមានយុត្តិកម្មក្នុងការពិចារណាលើការឃុំខ្លួនបណ្តោះអាសន្នឡើងវិញនោះទេ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ក្រុមមេធាវីការពារក្តីខកខានមិនបានផ្តល់ជាភស្តុតាងគាំទ្រលើភាពអាចអនុវត្តទៅបាននូវបទដ្ឋាន "ការយកចិត្តទុកដាក់ពិសេស" របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR) ហើយមិនបានផ្តល់ជាភស្តុតាងថ្មីណាមួយដែលអាចឱ្យអង្គបុរេជំនុំជម្រះជឿថា រយៈពេលនៃការឃុំខ្លួនមានភាពមិនសមស្របនោះឡើយ។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា រយៈពេលនៃការឃុំខ្លួនមានលក្ខណៈសមហេតុផល អនុលោមតាមមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ប្រសិនបើពិចារណាលើស្ថានទម្ងន់នៃបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់ភាពស្មុគស្មាញនៃរឿងក្តី ដំណើរការនៃកិច្ចដំណើរការនីតិវិធី និងវិសាលភាពនៃការស៊ើបអង្កេតដែលកំពុងបន្ត[៤៨]។

៤៧. អង្គបុរេជំនុំជម្រះបានយោងលើ បានលើកឡើងម្តងទៀត និងបានអនុម័តការយល់ឃើញ និងការសង្កេតជាទូទៅរបស់ខ្លួន នៅក្នុងសេចក្តីសម្រេចកាលពីលើកមុនលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ស្តីពីការយកចិត្តទុកដាក់ពិសេស[៤៩]។

៤៨. អង្គបុរេជំនុំជម្រះយល់ឃើញថែមទៀតថា ភាពសមស្របនៃរយៈពេលនៃការឃុំខ្លួន និងការយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេត នៅក្នុងការដឹកនាំកិច្ចស៊ើបសួររបស់ខ្លួន គឺជាកត្តាដែលត្រូវយកទៅពិចារណា នៅពេលអនុវត្តអំណាចឆន្ទានុសិទ្ធិក្នុងការពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។

[៤៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣៤ ដល់៣៦។

[៤៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១២ ដល់១៧។

[៤៩] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C20/5/18 កថាខណ្ឌ៥៥ ដល់៦០។

៤៩. អង្គបុរេជំនុំជម្រះយល់ឃើញថា មានភស្តុតាងបន្ថែមគ្រប់គ្រាន់នៅក្នុងសំណុំរឿង ដើម្បីកំណត់បង្ហាញថា កិច្ចស៊ើបសួរនានាបានដំណើរការទៅមុខយ៉ាងឆាប់រហ័ស នៅក្នុងអំឡុងពេលនៃការពិចារណា។ សហចៅក្រមស៊ើបអង្កេតបានផ្តល់នូវហេតុផលគ្រប់គ្រាន់ នៅក្នុងដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនដើម្បីគាំទ្រដល់ការយល់ឃើញនេះ។

៥០. អង្គបុរេជំនុំជម្រះយល់ឃើញថា ស្ថានទម្ងន់ និងលក្ខណៈនៃបទឧក្រិដ្ឋនានាដែលជនត្រូវចោទបានរងនូវការចោទប្រកាន់ តម្រូវឱ្យមានកិច្ចស៊ើបសួរដែលមានទំហំធំដែលបានធ្វើឡើងហើយ និងយល់ឃើញថា ដោយពិចារណាលើវិសាលភាពនិងដំណាក់កាលនៃកិច្ចស៊ើបសួរបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីបង្គាប់ឱ្យមានការពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នដោយសមហេតុផល។

## ឃ. សំណើសុំដោះលែងដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

៥១. នៅក្នុងបណ្ដឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការដោះលែងជនត្រូវចោទ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមលក្ខខណ្ឌទាំងឡាយដូចដែលបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបានស្នើសុំ[៥០]។

៥២. អង្គបុរេជំនុំជម្រះបានសម្រេចលើសំណើសុំដែលនេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០០៨ ដោយលើកឡើងថា "ជនត្រូវចោទមិនអាចត្រូវបានដោះលែងដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ ដោយសារតែភាពចាំបាច់ក្នុងការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទមានសារៈសំខាន់ខ្លាំងជាងលក្ខខណ្ឌនានា ដែលបានស្នើសុំដោយជនត្រូវចោទ [នៅក្នុងឧបសម្ព័ន្ធ គ ដែលបានភ្ជាប់ជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ]"[៥១]។

អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

---

[៥០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៣៨ ដល់៣៩។

[៥១] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C20/I/26 កថាខណ្ឌទី៧៥។

៥៣. ដោយសារតែសំណើសុំដោះលែង ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការគ្មានសេចក្តីសន្និដ្ឋានបន្ថែមទេនោះ អង្គបុរេជំនុំជម្រះបដិសេធសំណើសុំដោះលែងដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយគ្មានការបញ្ជាក់អំពីមូលហេតុថែមទៀតឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ**

១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់ច្បាប់។

២. តំកល់ដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ដោយមានមូលហេតុដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ៣៥ នៃសាលដីកានេះ ដែលជាមូលហេតុបន្ថែមលើមូលហេតុរបស់សហចៅក្រមស៊ើបអង្កេត។

៣. បដិសេធសំណើសុំឱ្យដោះលែង ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

៤. បដិសេធបណ្តឹងឧទ្ធរណ៍។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

សាលដីកានេះ **ប្រកាសជាសាធារណៈ** ដោយអង្គបុរេជំនុំជម្រះ នៅចំពោះមុខសហមេធាវីការពារក្តីរបស់គាត់។

ភ្នំពេញ ថ្ងៃទី៣០ ខែ[illegible] ឆ្នាំ២០[illegible]

**អង្គបុរេជំនុំជម្រះ**

**[illegible]**

Rowan DOWNING **ន័យ ថុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

**សរ ចំនួន[illegible]** Ant[illegible]la JOSIFI